# ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា

ព្រឹទ្ធសភា ជាចំណែកមួយ នៃអង្គនីតិប្បញ្ញត្តិរបស់ជាតិ ដែលបានរួមចំណែកក្នុងដំណើរការប្រជាធិបតេយ្យ ភាវូបនីយកម្មសង្គម និងការកសាងកម្ពុជាជានីតិរដ្ឋ ហើយបានរួមវិភាគទាននៅក្នុង ដំណើរការស្តេរភាវូបនីយកម្មជីវភាពនយោបាយរបស់ជាតិ ដែលជាស្នូលនៃការពង្រឹងនយោបាយ បង្រួប បង្រួម ផ្សះផ្សាជាតិ និងការអភិវឌ្ឍ។

## ១. ប្រវត្តិនៃការបង្កើតព្រឹទ្ធសភា

ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើងបន្ទាប់ពីកិច្ចប្រជុំរវាងថ្នាក់ដឹកនាំជាន់ខ្ពស់ គណបក្សនយោបាយ ធំៗទាំងពីរ នាថ្ងៃទី១២-១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ក្រោមព្រះរាជាធិបតីភាព ដ៏ខ្ពង់ខ្ពស់ របស់អតីតព្រះមហាក្សត្រ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ នៅព្រះបរមរាជវាំង។ កិច្ចប្រជុំដ៏សំខាន់នេះ បានបញ្ចប់វិបត្តិនយោបាយលើកកម្ពស់ការបង្រួបបង្រួមផ្សះផ្សាជាតិ និង ពង្រឹងស្ថេរភាពនយោបាយ ដោយបានឯកភាពគ្នាធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា តាមច្បាប់ធម្មនុញ្ញ ដែលបានប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ។

ការបង្កើតព្រឹទ្ធសភានេះ គឺជាព្រឹត្តិការណ៍នយោបាយដ៏ចម្បងមួយក្នុងប្រវត្តិសាស្ត្រកម្ពុជា ដែលបានបង្ហាញឱ្យឃើញនូវពន្លឺថ្មីមួយសម្រាប់អនាគតនៃប្រទេសកម្ពុជា ព្រមទាំងបង្ហាញឱ្យឃើញពីការប្តេជ្ញាចិត្តជាបន្តបន្ទាប់ក្នុងការកសាងលទ្ធិប្រជាធិបតេយ្យ និងការពង្រឹងនីតិរដ្ឋ។ ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី១ បានបើកសម័យប្រជុំ លើកទី១ នាថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩។

ព្រឹទ្ធសភានីតិកាលទី១ ( ១៩៩៩-២០០៦ ) កើតឡើងដោយការតែងតាំង មានសមាជិកចំនួន ៦១រូប ក្នុងនេះមានគណបក្សប្រជាជនកម្ពុជា ៣៣រូប ហ្វ៊ុនស៊ិនប៉ិច ២១រូប និងគណបក្សសមរង្ស៊ី ៧រូប ( ការបែងចែកអាសនៈ ទៅតាមចំនួនកូតានៃគណបក្សមានអាសនៈក្នុង

រដ្ឋសភានីតិកាលទី២ ) សម្រាប់ រយៈពេល ៥ឆ្នាំ ។ ព្រឹទ្ធសភានីតិកាលទី១ បានបន្តនីតិកាលរបស់ខ្លួនចំនួន២ដង(ម្តង១ឆ្នាំ)៖

– លើកទី១ ៖ ព្រះរាជសារចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៤ របស់ព្រះមហាក្សត្រ នរោត្តម សីហមុនី បានបន្តនីតិវិធី បោះឆ្នោតសម្ងាត់ក្នុងសម័យប្រជុំលើកទី៩ ព្រឹទ្ធសភា នីតិកាលទី១ នាថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៤ ដោយមានសំឡេង គាំទ្រចំនួន ៤៩សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ( គិតចាប់ពីថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៤ ដល់ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០០៥)។

– លើកទី២. ព្រះរាជសារចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៥ របស់ព្រះមហាក្សត្រ នរោត្តម សីហមុនី និងបានបន្តនីតិវិធី បោះឆ្នោតសម្ងាត់ក្នុងសម័យប្រជុំលើកទី៩ ព្រឹទ្ធសភា នីតិកាលទី១ នាថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០០៥ ដោយមានសំឡេងគាំទ្រ ចំនួន ៤៨ សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ( គិតចាប់ពីថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៥ ដល់ព្រឹទ្ធសភានីតិកាលទី២ ចូលកាន់តំណែង នាថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦ ) ។

ក្នុងនីតិកាលទី១នេះ ព្រឹទ្ធសភាបានផ្តួចផ្តើមគំនិតស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក ព្រឹទ្ធសភា ដែលរដ្ឋសភា បានអនុម័ត កាលពីថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំលើកទី២ នីតិកាលទី៣ ហើយព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់យល់ស្របលើទម្រង់ និងគតិច្បាប់នេះទាំងស្រុង នៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំលើកទី ៩ នីតិកាលទី១។ បន្ទាប់មក ក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញតាមសេចក្តីសម្រេចលេខ ០៧០/០០២/២០០៥ កបធ.ច ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ។ ច្បាប់នេះត្រូវបានប្រកាសឱ្យប្រើតាម ព្រះរាជក្រមលេខនស/រកម/០៦០៥/០២០ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៥ ។

ព្រឹទ្ធសភានីតិកាលទី២ (២០០៦-២០១២) កើតឡើងដោយការបោះឆ្នោតអសកលនាថ្ងៃអាទិត្យ ទី២២ ខែមករា ឆ្នាំ២០០៦ សម្រាប់រយៈពេល៦ឆ្នាំ ។ នីតិកាលទី២ សមាជិកព្រឹទ្ធសភាមានចំនួន ៦១រូប ដូចនីតិកាលទី១ ( ០២រូបចាត់តាំងដោយ ព្រះមហាក្សត្រ ០២រូបជ្រើសតាំងដោយរដ្ឋសភា និង ៥៧រូបជ្រើសតាំងដោយការបោះឆ្នោត ) ក្នុងនោះមានសមាជិកា ០៩រូប ។

ក្នុង៥៧រូប ដែលជ្រើសតាំង ដោយការបោះឆ្នោតមាន ៤៥រូបមកពីគណបក្សប្រជាជនកម្ពុជា ១០រូបមកពី គណបក្សហ្វ៊ុនស៊ិនប៉ិច និង ០២រូបមកពីគណបក្សសមរង្ស៊ី ។

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៣ បានប្រព្រឹត្តទៅនាថ្ងៃ អាទិត្យ ទី ២៩ ខែ មករា ឆ្នាំ ២០១២។ សម្រាប់នីតិកាលទី៣នេះ ចំនួនសមាជិកព្រឹទ្ធសភាមានចំនួន ៦១រូប ដូច នីតិកាលទី១ និងនីតិកាលទី២ ក្នុងនោះមាន សមាជិកាចំនួន ១០រូប ( មកពីគណបក្សប្រជាជនកម្ពុជា ០៦រូប សមរង្ស៊ី ០៣រូប និងជ្រើសតាំងដោយរដ្ឋសភា ០១រូប )។

## ២ . ការរៀបចំ និងការប្រព្រឹត្តទៅព្រឹទ្ធសភា

សម្រាប់ប្រទេសកម្ពុជា ព្រឹទ្ធសភាត្រូវបានបង្កើតឡើងតាមរយៈការបោះឆ្នោតផង និង តែងតាំងផងដែលសម្រាប់រយៈពេលមួយកំណត់ ជាមួយនឹងការប្រព្រឹត្តទៅដោយអនុវត្តតាម ច្បាប់ជាធរមាន។

### ២.១ ការរៀបចំព្រឹទ្ធសភា

សម្រាប់ប្រទេសកម្ពុជា សមាជិកព្រឹទ្ធសភា មានចំនួនយ៉ាងតិចស្មើនឹងពាក់កណ្ដាលនៃ ចំនួនសមាជិករដ្ឋសភា ហើយការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាត្រូវធ្វើឡើង ៦ ឆ្នាំ ម្ដងនៅថ្ងៃអាទិត្យ សប្ដាហ៍ទី៨ មុនដំណាច់ឆ្នាំទី៦នៃនីតិកាលព្រឹទ្ធសភា។ ការបោះឆ្នោតនេះ អនុវត្តទៅតាមប្រព័ន្ធសមាមាត្រ និងបែងចែកអាសនៈតាមមណ្ឌលត្រូវធ្វើតាមរូបមន្តមធ្យម ភាគខ្ពស់បំផុត។ មណ្ឌលបោះឆ្នោតត្រូវរៀបចំជា៨ភូមិភាគ។ ចំពោះអ្នកបោះឆ្នោត និងអង្គ បោះឆ្នោតគឺ តំណាងរាស្ត្រ និងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងតំណែងនៃភូមិភាគ នីមួយៗ។ បេក្ខជន សមាជិកព្រឹទ្ធសភាត្រូវមានអាយុយ៉ាងតិច ៤០ឆ្នាំ។

គណៈកម្មការរៀបចំការបោះឆ្នោត មានសមត្ថកិច្ចទទួលខុសត្រូវរៀបចំកិច្ចដំណើរការ នៃការបោះឆ្នោតហើយក្រុមប្រឹក្សាធម្មនុញ្ញជាស្ថាប័នតែមួយគត់ដែលមានសិទ្ធិ និងសមត្ថ កិច្ច ក្នុងការដោះស្រាយនូវរាល់វិវាទដែលពាក់ព័ន្ធនឹងដំណើរការនៃការបោះឆ្នោតជ្រើសតាំង សមាជិកព្រឹទ្ធសភា។ ការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្ដីសម្រេចបិទផ្លូវតវ៉ា។

ក្នុងសម័យប្រជុំដំបូងក្នុងនីតិកាលនីមួយៗ ដែលប្រារព្ធធ្វើឡើងក្នុងចន្លោះពេល៦០ថ្ងៃក្រោយការបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។ ព្រះមហាក្សត្រ ឬ ព្រះរាជតំណាង ទ្រង់ប្រទានឬ ផ្តល់កិត្តិយសចំពោះការបើកសម័យប្រជុំដំបូងនៃនីតិកាលនីមួយៗ។ នៅពេលបើកសម័យប្រជុំដំបូងនៃនីតិកាលនីមួយៗនៃព្រឹទ្ធសភា ត្រូវចាប់ផ្តើមក្រោមអធិបតីភាពនៃប្រធានបណ្តោះអាសន្ន ១ រូប ជាសមាជិកព្រឹទ្ធសភាជាប់ឆ្នោត ឬ ចាត់តាំងអាយុច្រើនជាងគេដែលវត្តមាន ហើយឥតមានបណ្តឹងតវ៉ា ព្រមទាំងសមាជិកព្រឹទ្ធសភាជាប់ឆ្នោត ឬ ចាត់ទាំងចំនួន ៥ រូប អាយុតិចជាងគេដែលវត្តមានជាលេខាធិការ ដើម្បីជួយប្រធានក្នុងកិច្ចការនេះ។

ក្រោមការដឹកនាំរបស់ប្រធានបណ្តោះអាសន្នខាងលើ ព្រឹទ្ធសភាត្រូវចាប់ផ្តើមការងារដូចតទៅ ៖

- **ប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ**
- **បោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានទាំងពីរនៃព្រឹទ្ធសភា**

**២.១.១ ការប្រកាសសុពលភាពសមាជិកព្រឹទ្ធសភា**

ដើម្បីប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗប្រធានបណ្តោះអាសន្តប្រកាសជូនអង្គប្រជុំនូវ ៖

- ឈ្មោះសមាជិកព្រឹទ្ធសភា ២ រូប ដែលព្រះមហាក្សត្រទ្រង់បានចាត់តាំង
- ឈ្មោះសមាជិកព្រឹទ្ធសភា ២ រូប ដែលរដ្ឋសភាបានជ្រើសតាំង
- ឈ្មោះសមាជិកព្រឹទ្ធសភាជាប់ឆ្នោតជាស្ថាពរ ដែលគណ:កម្មាធិការជាតិរៀបចំការបោះឆ្នោតបញ្ជូនមក
- ឈ្មោះសជិកព្រឹទ្ធសភាជាប់ឆ្នោតដែលមានបណ្តឹងតវ៉ា ហើយដែលក្រុមប្រឹក្សាធម្មនុញ្ញបានបដិសេធបណ្តឹងទាំងនោះ

ឈ្មោះសមាជិកព្រឹទ្ធសភាពេញសិទ្ធិទាំងអស់ត្រូវបិទផ្សាយភ្លាមក្នុងព្រឹទ្ធសភា និង ផ្សព្វផ្សាយជាសាធារណៈក្រោយពេលប្រជុំ និងត្រូវចុះផ្សាយក្នុងរាជកិច្ច។ សមាជិកព្រឹទ្ធសភាទាំងអស់ត្រូវធ្វើសច្ចាប្រណិធានមុនពេលចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ ន្ធទី ៧ នៃរដ្ឋធម្មនុញ្ញ។ ក្នុងករណីដែលអសនៈរបស់សមាជិកព្រឹទ្ធសភាដែលនៅទំនេរយ៉ាងតិច ៦ ខែ មុនចប់នីតិកាល ដោយហេតុសុំលាលែង បោះបង់ចោលការងារចំនួន ៣ ខែ គ្មានការអនុញ្ញាតដោយទទួលមរណភាព ដោយប្រាសចាកសមាជិកភាពព្រឹទ្ធសភា ឬ ដោយប្រាសចាកសមាជិកភាពពីគណបក្សនយោបាយត្រូវបំពេញជំនួសដោយសមាជិកព្រឹទ្ធសភាថ្មីចេញពីប្រភពដើមដែលមានអអាសនៈទំនេរនោះ។ ឈ្មោះសមាជិកព្រឹទ្ធសភាចូលជំនួសថ្មី ត្រូវប្រកាសជូនអង្គប្រជុំព្រឹទ្ធសភា ហើយត្រូវបិទផ្សាយក្នុងព្រឹទ្ធសភា និងផ្សព្វផ្សាយជាសាធារណៈ ព្រមទាំងចុះក្នុងរាជកិច្ច។

### ២.១.២ បោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានទាំងពីរនៃព្រឹទ្ធសភា

បើព្រឹទ្ធសភា មានសមាជិកវត្តមានលើសពីពាក់កណ្តាលនៃចំនួនសមាជិកទាំងមូល នោះប្រធានបណ្តោះអាសន្ន ត្រូវជម្រាបជូនគណបក្សនយោបាយ និងស្ថាប័នមានសអាសនៈក្នុងព្រឹទ្ធសភា ដើម្បីដាក់បេក្ខជនប្រធាន និងអនុប្រធានព្រឹទ្ធសភា។ ការបោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានទាំងពីររបស់ព្រឹទ្ធសភា ត្រូវធ្វើដាច់ដោយឡែកពីគ្នា តាមវិធីបោះឆ្នោតសម្ងាត់ ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។ បើការបោះឆ្នោតលើកទី ១ មិនបានសម្រេចត្រូវបោះឆ្នោតលើកទី២។ បើសម្លេងមិនបានសម្លេងគាំទ្រគ្រប់ចំនួនទៀត ត្រូវបោះឆ្នោតលើកទី៣។ បើមិនបានសម្លេងគាំទ្រទៀត ប្រធានបណ្តោះអាសន្ន ត្រូវជម្រាបជូនគណបក្សនយោបាយ ឬ ស្ថាប័នដែលមានអាសនៈនៅព្រឹទ្ធសភា ដើម្បីដាក់បេក្ខជនថ្មី ហើយត្រូវបន្តនីតិវិធីបោះឆ្នោតសាឡើងវិញ។

### ២.១.៣ គណៈកម្មការអចិន្ត្រៃយ៍នៃព្រឹទ្ធសភា

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ជាអង្គការដឹកនាំកំពូលរបស់ព្រឹទ្ធសភាដឹកនាំដោយប្រធានព្រឹទ្ធសភា ហើយមានអនុប្រធានទាំងពីរ និងប្រធានគណកម្មការនានារបស់ព្រឹទ្ធសភាជាសមាជិក។ គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាមានភារកិច្ចដូចតទៅ៖

- ដឹកនាំ ចាត់ចែង និងពិនិត្យសម្រេចរាល់ការងារ សកម្មភាពផ្សេងរបស់ព្រឹទ្ធសភា ក្នុងលក្ខខណ្ឌកំណត់នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា
- ចាត់ចែងការងាររបស់ព្រឹទ្ធសភា ក្នុងចន្លោះសម័យប្រជុំព្រឹទ្ធសភា
- រៀបចំរបៀបវារៈនៃពេលប្រជុំព្រឹទ្ធសភានីមួយៗ
- រៀបចំសមាសភាពលេខាធិការពីររូបសម្រាប់សម័យប្រជុំបន្ទាប់ដើម្បីដាក់ជូនអង្គប្រជុំព្រឹទ្ធសភាអនុម័ត
- ធានាការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- ធានាការគ្រប់គ្រង និងការចំណាយថវិកាព្រឹទ្ធសភាឲ្យប្រព្រឹត្តទៅបានត្រឹមត្រូវតាមការកំណត់ក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- ធានាការផ្តល់គ្រឿងឥស្សរិយយសជូនដល់សមាជិកព្រឹទ្ធសភា
- ធានាការអនុវត្តវិន័យក្នុងព្រឹទ្ធសភា
- លើកជូនព្រឹទ្ធសភាពិនិត្យ និងសម្រេចលើការស្នើចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួនសមាជិកព្រឹទ្ធសភាណាមួយ។ ក្នុងចន្លោះសម័យប្រជុំនៃព្រឹទ្ធសភា មានសិទ្ធិយល់ព្រមលើការស្នើចោទប្រកាន់ ចាប់ខ្លួន ឬ ឃុំខ្លួនសមាជិកណាមួយនៃព្រឹទ្ធសភា។ សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាត្រូវដាក់ជូនសម័យប្រជុំព្រឹទ្ធសភាខាងមុខដើម្បីអនុម័ត។
- លើកជូនព្រឹទ្ធសភាពិនិត្យ និងសម្រេចលើការផ្អាកការឃុំខ្លួន ការចោទប្រកាន់សមាជិកព្រឹទ្ធសភាណាមួយ។
- លើកជូនព្រឹទ្ធសភាពិនិត្យ និងសម្រេចអំពីការព្យួរអភ័យឯកសិទ្ធិសភា ការប្រគល់ជូនវិញនូវអភ័យឯកសិទ្ធិសភា ការបោះបង់ចោលការងារ វិសមិតភាព និងការប្រាសចាកសមាជិកព្រឹទ្ធសភា។

### ២.១.៤ គណៈកម្មការនានារបស់ព្រឹទ្ធសភា

បន្ទាប់ពីជ្រើសតាំងបាននូវប្រធាន និងអនុប្រធានទាំងពីរនៃព្រឹទ្ធសភារួចហើយនាដើមសម័យប្រជុំលើកទីមួយក្រោមអធិបតីភាពនៃប្រធានរបស់ខ្លួនព្រឹទ្ធសភាដំណើរការបោះឆ្នោតតាមបញ្ជីដាច់ដោយឡែកពីគ្នាជ្រើសតាំងសមាសភាពគណៈកម្មការជំនាញនានារបស់ព្រឹទ្ធ-សភាដោយយកសម្លេងអនុម័តភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។ ក្នុងករណីចាំបាច់ ការបោះឆ្នោតជ្រើសរើសគណៈកម្មការនានា អាចធ្វើឡើងច្រើនគណៈកម្មការក្នុងពេលតែមួយបាន។ សន្លឹកឆ្នោតតាមបញ្ជីរាយនាម និងហិបឆ្នោតត្រូវធ្វើដាច់ដោយឡែក។ បើការបោះឆ្នោតតាមបញ្ជីរាយនាមលើកទី១ មិនបានសម្រេច ការបោះឆ្នោតជាលើកទី២ និងលើកទី៣ ត្រូវធ្វើឡើងចំពោះតែបេក្ខជនដែលពុំទទួលបានសម្លេងគាំទ្រគ្រប់ចំនួនប៉ុណ្ណោះ បើការបោះឆ្នោតលើកទី៣ មិនបានសម្រេចទៀត ប្រធានព្រឹទ្ធសភាត្រូវជម្រាបជូនគណបក្សនយោបាយ និងស្ថាប័នដែលមានអាសនៈនៅក្នុងព្រឹទ្ធសភាឲ្យផ្លាស់ប្តូរបេក្ខជន និងធ្វើការបោះឆ្នោតតទៀត។ ក្រោយពីបានទទួលការគាំទ្រ ពីអង្គព្រឹទ្ធសភារួចហើយ មុននឹងចាប់ការងាររបស់ខ្លួនគណៈកម្មការនីមួយៗត្រូវកោះប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីបោះឆ្នោតជាសម្ងាត់ជ្រើសតាំងប្រធាន អនុប្រធាន និងលេខាធិការគណៈកម្មការនីមួយៗ។ គណៈកម្មការនីមួយៗមានសមាជិកយ៉ាងតិច ៥ រូប ហើយសមាជិកព្រឹទ្ធសភាមួយរូបៗ អាចឈរជាបេក្ខជនសមាជិកគណៈកម្មការបានតែមួយ។

គណៈកម្មការនីមួយៗត្រូវកំណត់តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនឲ្យស្របនឹងរដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងច្បាប់ជាធរមានរួចដាច់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យ និងសម្រេច។

ព្រឹទ្ធសភាមានគណៈកម្មការជំនាញនានាចំនួន១០៖

- គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត
- ២-គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

- ៣-គណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ ជនបទ និង បរិស្ថាន
- ៤-គណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារ សាធារណៈ
- ៥-គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និង ព័ត៌មាន
- ៦- គណៈកម្មការនីតិកម្ម និងយុត្តិធម៌
- ៧-គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និង ទេសចរណ៍
- ៨-គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះ បណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី
- ៩-គណៈកម្មការ សាធារណៈការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ១០-គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ ។

***សម្គាល់៖*** *គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ ជាគណៈកម្មការថ្មី កើតឡើងតាមរយៈការធ្វើវិសោធនកម្មប្រការ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានីតិកាលទី៣ ដែលប្រកាសឲ្យប្រើតាមសេចក្តីសម្រេចលេខ ០៩៧/០៩១៤/ពស.សរ ចុះថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ២០១៤ ដោយយោងតាមស្មារតី នៃកិច្ចព្រមព្រៀងស្តីពីការរៀបចំឡើងវិញនូវក្បាលម៉ាស៊ីនដឹកនាំព្រឹទ្ធសភា ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៤ និងកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៤។*

*ក្នុងករណីចាំបាច់ តាមការផ្តួចផ្តើមគំនិតរបស់ប្រធានព្រឹទ្ធសភា ឬ តាមសំណើររបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ឬ របស់សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន ព្រឹទ្ធសភាអាច*

សម្រេចបង្កើតគណៈកម្មការពិសេស ដែលមានសមាជិកច្រើន ឬ តិចតាមតម្រូវការសម្រាប់ធ្វើការងារច្បាស់លាស់ណាមួយរហូតដល់ចប់។

គណៈកម្មការពិសេស ត្រូវរាយការណ៍អំពីលទ្ធផលការងាររបស់ខ្លួនជូនគណៈកម្មាធិការអចិន្ត្រៃយ៍នៃព្រឹទ្ធសភា ហើយមានសិទ្ធិស្នើសុំជំនួយការ មធ្យោបាយ និងថវិកាសម្រាប់បំពេញការងារ។

### ២.១.៥ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទទួលបន្ទុកធ្វើកំណត់ហេតុរបស់ព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មការនានារបស់ព្រឹទ្ធសភា និងទទួលរ៉ាប់រងរាល់កិច្ចការរាល់បាលសន្តិសុខ និងសេវាទាំងឡាយរបស់ព្រឹទ្ធសភា ព្រមទាំងទំនាក់ទំនងផ្សេងៗក្រៅព្រឹទ្ធសភា ក្រោមការដឹកនាំ និងត្រួតពិនិត្យរបស់ប្រធានព្រឹទ្ធសភា។

អគ្គលេខាធិការដ្ឋាន ត្រូវដឹកនាំដោយអគ្គលេខាធិកាមួយរូប និងមានអគ្គលេខាធិការរងជាជំនួយ ដែលអ្នកទាំងពីរត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីជាន់ខ្ពស់ដែលមានបទពិសោធន៍ក្នុងកិច្ចការសភា ឬ រដ្ឋបាលយ៉ាងតិច ១០ ឆ្នាំ ហើយដែលមិនមែនជាសមាជិកព្រឹទ្ធសភា និងមិនមែនជាអ្នកដឹកនាំគណបក្សនយោបាយ ហើយត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើររបស់ប្រធានព្រឹទ្ធសភា ក្រោយពីបានឯកភាពជាមួយអនុប្រធានទី១ និងអនុប្រធានទី២។ ចំពោះបុគ្គលិកទាំងអស់របស់លេខាធិការដ្ឋាន ត្រូវតែងតាំងដោយប្រធានព្រឹទ្ធសភា ស្របតាមច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិ។

### ២.២ ការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា

ព្រឹទ្ធសភាប្រជុំជាសាមញ្ញ២ដងក្នុងមួយឆ្នាំ។ សម័យប្រជុំនីមួយៗមានថិរវេលាយ៉ាងតិច ៣ខែ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬ សេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬ ពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគបីយ៉ាងតិច ព្រឹទ្ធសភាកោះប្រជុំជាវិសាមញ្ញ (មាត្រា១០៧ថ្មី នៃ រដ្ឋធម្មនុញ្ញ)។ ការប្រជុំព្រឹទ្ធសភា ត្រូវធ្វើជាសាធារណៈ និងត្រូវផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍

ជាតិ។ កំណត់ហេតុនៃការប្រជុំព្រឹទ្ធសភា មានកំណត់ហេតុសង្ខេប និងកំណត់ហេតុពិស្តារ។ កំណត់ហេតុទាំងអស់ត្រូវរក្សាទុកនៅក្នុងបណ្ណសារដ្ឋានព្រឹទ្ធសភា។ ព្រឹទ្ធសភាអាចកោះប្រជុំជាសម្ងាត់បានតាមសំណើសុំពីប្រធាន ឬ ពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគដប់យ៉ាងតិច ឬ ពីព្រះមហាក្សត្រ ឬ ពីនាយករដ្ឋមន្ត្រី ឬ ពីប្រធានរដ្ឋ។ កាលណាព្រឹទ្ធសភាសម្រេចថា ត្រូវប្រជុំជាសម្ងាត់ ប្រធានព្រឹទ្ធសភា និងលេខាធិការសម័យប្រជុំមើលឲ្យច្បាស់ជាមុនសិនថា ពិតជាគ្មានមនុស្សដទៃក្រៅពីសមាជិកព្រឹទ្ធសភា លេខាធិការ និងឥស្សរជនដែលព្រឹទ្ធសភាត្រូវការចាំបាច់នៅក្នុងសាលប្រជុំ។ ក្នុងករណីនេះ នៅមុនពេលបិទការប្រជុំ ព្រឹទ្ធសភាត្រូវអនុម័តថា អនុញ្ញាត ឬ មិនអនុញ្ញាតឲ្យបោះផ្សាយកំណត់ហេតុប្រជុំ។

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ជាអ្នករៀបចំរបៀបវារៈក្នុងសម័យប្រជុំនីមួយៗ នៅចុងបញ្ចប់នៃការប្រជុំ ប្រធានត្រូវអានរបៀបវារៈសម្រាប់ពេលប្រជុំបន្ត។ របៀបវារៈមានលំដាប់មុនក្រោយដូចតទៅ ៖

- បញ្ហាទាំងឡាយដែលមានសំណើរសុំចាត់ជាប្រញាប់
- បញ្ហាទាំងឡាយដែលរដ្ឋសភាជូនមកព្រឹទ្ធសភា
- បញ្ហាទាំងឡាយដែលរាជរដ្ឋាភិបាលជូនមកព្រឹទ្ធសភា
- បញ្ហាទាំងឡាយដែលគណៈកម្មការនានាជូនមកព្រឹទ្ធសភា
- បញ្ហាទាំងឡាយដែលសមាជិកព្រឹទ្ធសភាជូនមកព្រឹទ្ធសភា

**ការប្រជុំព្រឹទ្ធសភានឹងយកជាការបានលុះត្រាតែមាន ៖**

ក- កូរ៉ុមលើសពីពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូលសម្រាប់ការអនុម័តទាំងឡាយណា ដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

ខ- កូរ៉ុមលើសពីពាក់កណ្ដាល នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណា ដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬ មតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។ កូរ៉ុម ត្រូវតែមានគ្រប់ចំនួននៅពេលបើកការប្រជុំ និងនៅ

ពេលអនុម័ត។ បើកូរ៉ុមមិនគ្រប់ក្នុងរយៈពេល ៣០នាទី ក្រោយពេលកំណត់ចាប់ផ្តើមការប្រជុំ ប្រធានព្រឹទ្ធសភាត្រូវលើកពេលប្រជុំ (ប្រការ៤១ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា)។

### ៣. សិទ្ធិ និងករណីកិច្ចរបស់សមាជិកព្រឹទ្ធសភា

សមាជិកព្រឹទ្ធសភាទទួលបានអភ័យឯកសិទ្ធិ និងមានមុខងារជាក់លាក់ដើម្បីបំពេញការងារ។ រដ្ឋធម្មនុញ្ញបានកំណត់ថា ការចាប់ខ្លួន និងឃុំខ្លួនសមាជិកព្រឹទ្ធសភាបាន លុះត្រាតែមានការយល់ព្រមពីប្រធានព្រឹទ្ធសភា។ មានន័យថា គេត្រូវមានការយល់ព្រមពីប្រធានព្រឹទ្ធសភាជាមុនសិនទើបសមាជិកទាំងនោះត្រូវបានចាប់ខ្លួនពីបទល្មើសណាមួយ។ លើកលែងតែករណីមួយចំនួនដូចជាបទល្មើសជាក់ស្តែង ត្រូវជូនដំណឹងទៅព្រឹទ្ធសភាជាបន្ទាន់ ឬ ទៅគណៈកម្មាធិការអចិន្ត្រៃយ៍នៅចន្លោះសម័យប្រជុំព្រឹទ្ធសភា ដើម្បីធ្វើការសម្រេច។ សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ត្រូវដាក់ជូនសម័យប្រជុំព្រឹទ្ធសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើន ២/៣ នៃសមាជិកព្រឹទ្ធសភាទាំងមូល។ ក្នុងករណីនេះ ការឃុំខ្លួន ការចោទប្រកាន់សមាជិកព្រឹទ្ធសភាណាមួយត្រូវផ្អាក ប្រសិនបើព្រឹទ្ធសភាបានបញ្ចេញមតិឲ្យផ្អាកតាមមតិភាគច្រើន ៣/៤ នៃសមាជិកព្រឹទ្ធសភាទាំងមូល។ អភ័យឯកសិទ្ធិរួចផុតពីការចោទប្រកាន់នេះមានចែងនៅក្នុងមាត្រា ១០៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

សមាជិកព្រឹទ្ធសភា មិនអាចឈប់ក្នុងថ្ងៃបំពេញការងារ ឬ ក្នុងថ្ងៃប្រជុំព្រឹទ្ធសភាដោយមិនមានការអនុញ្ញាតពីប្រធានព្រឹទ្ធសភាបានឡើយ ដែលពាក្យសុំច្បាប់ត្រូវបញ្ជូនមកយ៉ាងយឺតបំផុត ៣ ថ្ងៃមុនថ្ងៃឈប់ លើកលែងតែពាក្យសុំច្បាប់ក្នុងថ្ងៃប្រជុំបន្ថយមកត្រឹម ១ ថ្ងៃ។ ការឈប់ក្នុងថ្ងៃបំពេញការងារ ដោយមូលហេតុមានជំងឺរយៈពេល ១៥ ថ្ងៃ ជាប់ៗគ្នា ត្រូវមានសំបុត្រពេទ្យយកមកសំអាង។ សមាជិកព្រឹទ្ធសភា ដែលបានទទួលលិខិតអញ្ជើញប្រជុំ ឬ ទទួលបានការប្រាប់ផ្ទាល់មាត់ ឬ បានទទួលដំណឹងតាមគ្រប់មធ្យោបាយផ្សេងៗ ត្រូវចូលប្រជុំតាមការអញ្ជើញ។ ការមិនចូលប្រជុំតាមការអញ្ជើញ ចាត់ទុកថាជាការខានមកប្រជុំដោយគ្មានការអនុញ្ញាត។

## ៤. មុខងារព្រឹទ្ធសភា

ជាស្ថាប័នកំពូលមួយរបស់រដ្ឋ បន្ទាប់ពីស្ថាប័នព្រះមហាក្សត្រ ព្រឹទ្ធសភាដើរតួនាទីយ៉ាងសំខាន់ក្នុងកិច្ចការរៀបចំ និងដឹកនាំប្រទេសជាតិដោយស្របទៅតាមរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។ នៅក្នុងការបំពេញបេសកកម្មរបស់ខ្លួនព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា មានមុខងារសំខាន់ៗមួយចំនួនដូចជាខាងក្រោម៖

### ៤.១ មុខងារនីតិកម្ម

ពិនិត្យអោយយោបល់លើអត្ថបទច្បាប់ដែលអនុម័តដោយរដ្ឋសភា និងផ្តួចផ្តើមធ្វើសេចក្តីស្នើច្បាប់។ តួនាទីសំខាន់របស់ ព្រឹទ្ធសភា គឺ ការពិនិត្យឡើង វិញរាល់អត្ថបទច្បាប់ទាំងឡាយដែលរដ្ឋសភាបានអនុម័តរួចហើយ។ រដ្ឋសភាមិនអាចបញ្ជូន ច្បាប់ដែលខ្លួនបានអនុម័ត រួចហើយអោយ ព្រះមហាក្សត្រឡាយ ព្រះហស្តលេខា ប្រកាសអោយប្រើជា ផ្លូវការមុនពេលដាក់ឆ្លងអោយ ព្រឹទ្ធសភាពិនិត្យបានឡើយ។ ព្រឹទ្ធសភាមានអំណាចត្រួត ពិនិត្យព្រមទាំងធ្វើអនុសាសន៍ទៅ លើពង្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ ដែលត្រូវបាន អនុម័តដោយរដ្ឋសភា។ ទោះបីជាព្រឹទ្ធសភាអាចធ្វើការបដិសេធ ឬ ស្នើអោយ ធ្វើវិសោធនកម្មទៅលើអត្ថបទច្បាប់ ព្រឹទ្ធសភាពុំមានអំណាចចាប់បង្ខំអោយ រដ្ឋសភា ទទួលយកអនុសាសន៍របស់ខ្លួនឡើយ។ ចំណែកឯរដ្ឋសភាវិញ អាចបដិសេធ មិនទទួលអនុសាសន៍របស់ ព្រឹទ្ធសភា ហើយនឹង អាចអនុម័តអោយចេញនូវច្បាប់ដែល ព្រឹទ្ធសភាបានបដិសេធ។ច្បាប់ណាក៏ដោយ បើទោះបីជាព្រឹទ្ធសភាបដិសេធតែទីបំផុតនៅតែត្រូវបាន រដ្ឋសភាអនុម័ត ហើយដាក់ថ្វាយព្រះមហាក្សត្រ ឡាយព្រះហស្តលេខា និងប្រកាសអោយប្រើ។ រដ្ឋធម្មនុញ្ញ មិនបានផ្តល់អោយព្រឹទ្ធសភានូវអំណាច អនុម័តនូវច្បាប់ ឬ អំណាចជំទាស់អត្ថបទច្បាប់ ឡើយប៉ុន្តែផ្តល់អោយនូវតួនាទីប្រឹក្សា ឬ អំណាចធ្វើអនុសាសន៍ ដែលរដ្ឋសភាបានអនុម័ត។

ព្រឹទ្ធសភាសហការជាមួយរដ្ឋសភានិងរាជរដ្ឋាភិបាល ដើម្បីរៀបចំអោយបានចេញជារូបរាងនូវកម្មវិធីនិងប្រតិទិននៃការ កសាងច្បាប់ សម្រាប់ ឆ្នាំនីមួយៗ។ ព្រឹទ្ធសភាផ្តល់យោបល់លើអត្ថបទច្បាប់ក្នុងរយៈពេលមួយខែយ៉ាងយូរ ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើក

ដំបូងរួចហើយព្រមទាំងលើបញ្ហាទាំងពួងដែលរដ្ឋសភាបាន ដាក់បើជាការប្រញាប់ អោយពិនិត្យ។ បើជាការប្រញាប់រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ។ បើព្រឹទ្ធសភាអោយយោបល់ព្រមឬពុំបានអោយយោបល់សោះក្នុងរយៈពេលដែលមានកំណត់ទុកហើយនោះទេច្បាប់ ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះ នឹងត្រូវបានយកទៅប្រកាសអោយប្រើ។

បើព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជាអសារបង់ រដ្ឋសភាមិនអាច នឹងយកមកពិចារណាជាលើកទីពីរបានមុនរយៈពេលមួយខែទេ ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ប្រាំថ្ងៃ បើពិនិត្យពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែបួនថ្ងៃ បើជាការប្រញាប់។

ព្រឹទ្ធសភា មានអំណាចចំពោះការផ្តួចផ្តើមធ្វើច្បាប់និងអនុម័តប៉ុន្តែមិនមានអំណាចសម្រេចជាចុងក្រោយថាតើច្បាប់ទាំងនោះ ចូលជាធរមាន ឬ អត់នោះទេ។ មានតែរដ្ឋសភាមួយគត់ ដែលមានអំណាចនោះ។ មាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញ ផ្តល់អំណាចនេះអោយទៅព្រឹទ្ធសភាដោយ ចែងថា «សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រីមានសិទ្ធិ ផ្តួចផ្តើមគំនិតធ្វើ ច្បាប់»។ ចំពោះការកែសម្រួល ឬ បដិសេធច្បាប់ព្រឹទ្ធសភាមានសិទ្ធិសុំអោយកែសម្រួល ឬ បដិសេធអត្ថបទច្បាប់នោះក្នុងករណីនេះរដ្ឋសភា ត្រូវយកមកពិចារណាភ្លាមជាលើកទីពីរ។ រដ្ឋសភាត្រូវពិនិត្យ និងសម្រេចតែត្រង់បទប្បញ្ញត្តិ ឬចំណុចណា ដែលព្រឹទ្ធសភាសុំអោយកែ សម្រួលដោយបដិសេធចោលទាំងមូល ឬ ទុកជាបានការខ្លះ។

### ៤.២ មុខងារត្រួតពិនិត្យ

ព្រឹទ្ធសភាអាចតាមដានត្រួតពិនិត្យការងារ និងការអនុវត្តន៍គោលនយោបាយផ្សេងៗរបស់រាជរដ្ឋាភិបាលជាពិសេសត្រួតពិនិត្យការប្រើប្រាស់ ថវិកាជាតិរបស់រាជរដ្ឋាភិបាល។ ព្រឹទ្ធសភាដើរតួនាទីសំខាន់ក្នុងការតាមដានដំណើរការការងាររបស់ស្ថាប័នរដ្ឋ និងត្រួតពិនិត្យយ៉ាងទៀងទាត់ អំពីការអនុវត្តន៍ច្បាប់របស់ស្ថាប័ននីតិប្រតិបត្តិ។ ព្រឹទ្ធសភាក៏ដើរតួនាទីសំខាន់ក្នុងការអនុវត្តន៍នូវកម្មវិធីនិងផែនការរបស់រាជរដ្ឋាភិបាលលើការងារប្រជាធិបតេយ្យ

នីតិរដ្ឋ ការងារ កែ ទម្រង់ រដ្ឋ ការងារកាត់បន្ថយភាពក្រីក្រ ការងារ អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច។

ព្រឹទ្ធសភាប្រមូលបញ្ហារសើបពីប្រភពផ្សេងៗ តាមរយៈឯកសារអនាមិកជួបសម្ភាសន៍អ្នកឯកទេស ពាក់ព័ន្ធ សិក្សាវិភាគលើទិដ្ឋភាពផ្សេងៗ ឯកសារយោងបទដ្ឋានគតិយុត្តិ ឬសំណុំរឿងប្រហាក់ប្រហែល សហការជាមួយ អាជ្ញាធរ មូលដ្ឋាន សង្គមស៊ីវិល និងប្រជាពលរដ្ឋ ដល់ទីកន្លែង។

ប្រសិនបើឃើញថា មានការខ្វះខាតលើអត្ថបទច្បាប់ណាមួយព្រឹទ្ធសភាអាចស្នើសុំអោយ រាជរដ្ឋាភិបាល ឬ រដ្ឋមន្ត្រីពាក់ព័ន្ធមកបំភ្លឺ និងអាចផ្តល់ជាអនុសាសន៍កែលំអរឡើងវិញក្នុងន័យស្ថាបនា។

ព្រឹទ្ធសភាដើរតួនាទីសំខាន់ក្នុងការតាមដានលើ របាយការណ៍សកម្មភាពរបស់រាជរដ្ឋាភិបាល ឬរបស់ក្រសួងដើម្បីទទួលបាននូវព័ត៌មានដ៏សំខាន់។ ករណីនេះបើសិនជាព្រឹទ្ធសភាពិនិត្យលើរបាយការណ៍ឃើញថាមានការខ្វះចន្លោះ ឬចំណុចខ្សោយត្រង់ណានោះ ព្រឹទ្ធសភាអាចធ្វើជារបាយការណ៍ទៅរាជរដ្ឋាភិបាលដើម្បីផ្តល់ជាយោបល់កែលំអរ និងជាការរួមចំណែកក្នុងយន្តការស្ថាបនាចំណុចខ្វះខាតនោះអោយមានលក្ខណៈល្អឡើងវិញ។

## ៤.៣ មុខងារជាតំណាង

ក្នុងមុខងារជាតំណាងនេះ ព្រឹទ្ធសភា មិនមែនត្រឹមតែជាតំណាងឲ្យសមូហភាពដែនដីដែលបានបោះឆ្នោតជ្រើសតាំងនោះទេ គឺតំណាងឲ្យស្ថាប័នជាតិ និងប្រជាជាតិទាំងមូលផងដែរ។

### ក. តំណាងសមូហភាពដែនដី(ក្រុមប្រឹក្សាឃុំ-សង្កាត់)

ព្រឹទ្ធសភាតំណាងអោយភូមិភាគ និងសមូហភាពដែនដី (ក្រុមប្រឹក្សាឃុំ-សង្កាត់) មាត្រា៩ និង មាត្រា១១ នៃច្បាប់ស្តីពីការ បោះឆ្នោត ជ្រើស តាំង សមាជិកព្រឹទ្ធសភា បានបង្ហាញច្បាស់អំពីអត្តសញ្ញាណរបស់សមាជិកព្រឹទ្ធសភា។ ក្នុងតួនាទីជាអ្នកតំណាងអោយក្រុមប្រឹក្សាឃុំ

សង្កាត់ដែលជាស្ពានតភ្ជាប់នូវកិច្ចទំនាក់ទំនងរវាងមូលដ្ឋានដែនដី និងរាជរដ្ឋាភិបាល ព្រឹទ្ធសភាចាំបាច់ត្រូវតែផ្តោតការយកចិត្តទុក ដាក់ជាពិសេសទៅលើផលប្រយោជន៍របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងភូមិភាគ។

បន្ទាប់ពីការបោះឆ្នោតជាអសកលលើកដំបូងដើម្បីជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី២ នាថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៦ មក ព្រឹទ្ធសភាមានទម្ងន់នយោបាយមួយតាមរយៈ ការពង្រឹងដំណើរការពិនិត្យ តាមដានការអនុវត្តន៍គោល នយោបាយវិមជ្ឈការ វិសហមជ្ឈការ ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានចាប់ផ្តើមតាំងពីឆ្នាំ ២០០២ មក។ បច្ចុប្បន្ន ក្នុងចំនួនប្រជាជនសរុបជាង ១៤លាននាក់ ត្រូវតំណាង អោយ ឃុំសង្កាត់ ចំនួន ១៦២១ ក្នុងនោះមានសមាជិកក្រុម ប្រឹក្សាឃុំ-សង្កាត់ សរុបចំនួន ១១៣៥៣នាក់ ដែលត្រូវបាន ប្រជាជនផ្តល់នូវជំនឿទុកចិត្ត និងសេចក្តីសង្ឃឹមជឿជាក់។ ដូច្នេះ ព្រឹទ្ធសភាគឺជាចំណុច ប្រសព្វនៃដំណើរការជ្រើសរើស សម្រិតសម្រាំង និងភាពជំរុញ ដោយ ហេតុផល។

### ខ. តំណាងស្ថាប័នជាតិ

សមាជិក ០២រូប តែងតាំងដោយព្រះមហាក្សត្រ និង ០២រូបទៀតតែងតាំងដោយរដ្ឋសភា។ ព្រឹទ្ធសភាក៏តំណាងអោយ ព្រះមហាក្សត្រ និងរដ្ឋ សភា ហើយក៏ជាអ្នកសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាលមាត្រា ១១២ បញ្ជាក់ថា «ព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល»។ នេះបើតាមទ្រឹស្តី ជាតួនាទីមួយដែលសំខាន់បំផុត ដែលអនុញ្ញាតអោយព្រឹទ្ធសភា អនុវត្តនូវឥទ្ធិពលមួយសំខាន់លើការងាររបស់ស្ថាប័ន ទាំងពីរ គឺរាជរដ្ឋាភិបាល និង រដ្ឋសភា។

ប៉ុន្តែតួនាទីនេះមិនត្រូវបានអនុវត្តដោយមានប្រសិទ្ធភាពទេ។ មាត្រា១១២ចែងតែគោលការណ៍ដោយមិនបញ្ជាក់ពី សារធាតុ ដែលមាន នៅ ក្នុងនោះទេ។ ក្រុមប្រឹក្សាធម្មនុញ្ញក៏មិន បានបញ្ជាក់អោយច្បាស់ជាងនេះដែរ។ សេចក្តីសម្រេច របស់ក្រុមប្រឹក្សាធម្មនុញ្ញនេះគ្រាន់ តែ បញ្ជាក់ ថាវាគ្រាន់តែជាតួនាទីនយោបាយរបស់ព្រឹទ្ធសភា ដែលមិនអាចកំណត់បានដោយអត្ថបទច្បាប់ ឬបទបញ្ជាណាមួយបានទេ។ ព្រឹទ្ធសភា ត្រូវតែប្រើប្រាស់គ្រប់

មធ្យោបាយ និងអាចធ្វើអន្តរាគមន៍បាន គ្រប់ពេលវេលា ដើម្បីដោះស្រាយវិបត្តិនយោបាយ តូច ឬធំ រវាងស្ថាប័នទាំងពីរ។ ព្រឹទ្ធសភាមិនអាចបង្ខំទស្សនៈរបស់ ខ្លួនអោយរដ្ឋសភា និងរាជរដ្ឋាភិបាលគោរពតាមដោយ ឆន្ទានុសិទ្ធិបានទេ។ និយាយផ្សេងពីនេះ ទៀតតួនាទី នេះមិនចង ស្ថាប័នទាំងពីរនេះទេ។ ចុងបញ្ចប់សេចក្តីសម្រេចក្រុម ប្រឹក្សាធម្មនុញ្ញនេះ បញ្ជាក់ថា តួនាទី នេះ ចាត់ទុកថាមាន លទ្ធផល វិជ្ជមាន នៅពេលដែលមានការស្រុះស្រួលគ្នា រវាងស្ថាប័នទាំង ពីរ។

### គ. តំណាងប្រជាជាតិទាំងមូល

សមាជិកព្រឹទ្ធសភាភាគច្រើនត្រូវបានជ្រើសតាំង ដោយការបោះឆ្នោតជាអសកលមិន ចំពោះ និងតាមវិធីជ្រើសរើស បោះឆ្នោតជាសម្ងាត់ តំណាងអោយក្រុមប្រឹក្សាឃុំ-សង្កាត់ ដែល ប្រមូលផ្តុំនៅក្នុងភូមិភាគទាំង៨។ ព្រឹទ្ធសភាមាន កាតព្វកិច្ច ចូលរួម ចំណែកយ៉ាងខ្ជាប់ខ្ជួនក្នុង ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងជួយផ្តល់អនុសាសន៍ ដើម្បីតម្រង់ទិស លើការ អនុវត្តន៍ ជាក់ស្តែងអោយបានប្រកបដោយ លទ្ធផលផ្លែផ្កាពិតប្រាកដដល់ឃុំសង្កាត់ទូទាំង ប្រទេស និងភូមិភាគ។ ប្រការនេះមានការពាក់ព័ន្ធ ដល់ការដ្ឋាន ដ៏ធំដែល រាជរដ្ឋាភិបាល កំពុងខិតខំប្រឹងប្រែង ក្នុង ការកែទម្រង់ការគ្រប់គ្រង រដ្ឋបាលសាធារណៈ និងការបង្ហិត ប្រជាធិបតេយ្យ អោយទៅដល់ថ្នាក់មូលដ្ឋានជិត ប្រជាជន នោះគឺជាការអនុវត្តន៍គោលនយោ បាយ វិមជ្ឈការ និងវិសហមជ្ឈការដើម្បី អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងការកាត់ បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋ។

ភាពជាតំណាងបែបនេះមានចរិតពិសេសត្រង់ថា សមាជិកព្រឹទ្ធសភា គឺជាអ្នកជាប់ ឆ្នោត តាមការជ្រើសតាំងដោយអ្នក ជាប់ ឆ្នោតទទួល បន្ទុក គ្រប់គ្រងដឹកនាំឃុំ-សង្កាត់ទូទាំង ប្រទេស និងតំណាងរាស្ត្រក្នុងតំណែង។ ក្នុងភាពជាអ្នកតំណាងក្រុមប្រឹក្សាឃុំ -សង្កាត់ នាំ អោយព្រឹទ្ធសភាមានបេសកកម្មផ្ទាល់របស់ខ្លួន ក្នុងលក្ខណៈពិសេសមួយដោយត្រូវផ្សាភ្ជាប់ ការងាររបស់ខ្លួនទៅ នឹងកិច្ចការពារ និងជំរុញផលប្រយោជន៍របស់ក្រុមប្រឹក្សាឃុំសង្កាត់ទូទាំង ប្រទេសរួមទាំងភូមិភាគទាំង ៨ទៀតផង។ ការជំរុញផលប្រយោជន៍របស់ក្រុមប្រឹក្សាឃុំសង្កាត់ ទូទាំងប្រទេសនេះ គឺជាការជំរុញផលប្រយោជន៍ប្រជាពលរដ្ឋទូទាំងប្រទេស។

## ៥. ភាពខុសគ្នារវាងរដ្ឋសភា និងព្រឹទ្ធសភា

ព្រឹទ្ធសភា និងរដ្ឋសភា ជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិដូចគ្នា តែរដ្ឋសភា និងព្រឹទ្ធសភាមានអត្តសញ្ញាណ និងសមត្ថកិច្ចខុសគ្នាអាស្រ័យដោយៈ

### ៥.១ ប្រភព

តំណាងរាស្ត្រទាំងអស់ ត្រូវជ្រើសតាំងដោយការបោះឆ្នោតសកល ដោយប្រជារាស្ត្រតាមមណ្ឌលខេត្ត-រាជធានីសំរាប់រយៈពេល៥ឆ្នាំ។ សមាជិកព្រឹទ្ធសភាត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកលដោយក្រុមប្រឹក្សាឃុំ-សង្កាត់ និងតំណាងរាស្ត្រក្នុងតំណែងតាមភូមិភាគសម្រាប់រយៈពេល៦ឆ្នាំ រួមជាមួយនោះ មាន២រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ និង២រូបទៀតត្រូវបានជ្រើសតាំងដោយរដ្ឋសភា។ ដូច្នេះលក្ខណៈពិសេសរបស់ព្រឹទ្ធសភា គឺព្រឹទ្ធសភាកើតដោយការបោះឆ្នោតជ្រើសតាំង ផង និងដោយការចាត់តាំងផង។

### ៥.២ ភាពតំណាង

តំណាងរាស្ត្រ ជាតំណាងរបស់ប្រជាពលរដ្ឋទូទៅជាម្ចាស់ឆ្នោតក្នុងមណ្ឌល។ បេក្ខជនតំណាងរាស្ត្រមានអាយុយ៉ាងតិច២៥ឆ្នាំ។ ចំណែកសមាជិកព្រឹទ្ធសភា ភាគច្រើនជាតំណាងក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលជាម្ចាស់ឆ្នោតនៅក្នុងភូមិភាគ។ ប៉ុន្តែក៏មានតំណាងព្រះមហាក្សត្រ២រូប និង២រូបទៀតជ្រើសតាំងដោយរដ្ឋសភា។ វត្តមាននៃតំណាងស្ថាប័នជាន់ខ្ពស់ទាំងពីរនេះ រួមទាំងភាពជាតំណាងសមូហភាពដែនដី ធ្វើឱ្យព្រឹទ្ធសភាមានតួនាទីពិសេស ជាស្ពានតភ្ជាប់អំណាចរដ្ឋពីថ្នាក់លើទៅថ្នាក់មូលដ្ឋានជាប់នឹងប្រជារាស្ត្រ។បេក្ខជនសមាជិកព្រឹទ្ធសភាមានអាយុយ៉ាងតិច៤០ឆ្នាំ។ ដូចនេះលក្ខណៈខុសគ្នារវាងព្រឹទ្ធសភា និងរដ្ឋសភា គឺ ភាពជាតំណាងខុសគ្នាការយកចិត្តទុកដាក់ក៏ខុសគ្នា, មណ្ឌលរបស់តំណាងរាស្ត្រ ជារាជធានី ខេត្ត ចំណែកមណ្ឌលរបស់សមាជិកព្រឹទ្ធសភា ជាភូមិភាគ ដែលភាគច្រើនជាការប្រមូលផ្តុំខេត្តចាប់ពីពីរឡើងទៅ។

ភាពខុសគ្នាខាងអាយុពុំមែនដោយអត់ហេតុផលឡើយ។ ភាពចាស់ទុំខាងនយោបាយ បទពិសោធន៍ ស្មារតីទទួលខុសត្រូវ និងសីលធម៌ខ្ពស់ជាកត្តាចម្បងនៃការជ្រើសរើសសម្រិតសម្រាំង ព្រោះសមាជិកព្រឹទ្ធសភាត្រូវជ្រើសតាំងដោយអ្នកជាប់ឆ្នោត និងចាត់តាំងដោយព្រះមហាក្សត្រ។ នេះក៏ជាចំណុចកត់សម្គាល់អំពីភាពខុសគ្នារវាងសភាទាំងពីរនៅក្នុងការអនុវត្ដការងារ ជាក់ស្តែង ។ ការឱ្យយោបល់ប្រកបដោយគតិបណ្ឌិត ការណែនាំ និងការបង្ហាញផ្លូវ

ជាការយកចិត្តទុកដាក់របស់ព្រឹទ្ធសភា។ ភាពខុសគ្នាខាងប្រព័ន្ធបោះឆ្នោត អង្គបោះឆ្នោត រយៈពេលនៃនីតិកាលបង្ហាញនូវលក្ខណៈ ពិសេសផ្ទាល់ និងអត្តសញ្ញាណផ្ទាល់របស់សភានីមួយៗ។

**៥.៣ អំណាច**

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល (មាត្រា ៩០ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ) និងអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬ ទម្លាក់រាជរដ្ឋាភិបាលពីតំណែង(មាត្រា៩៨ថ្មី នៃរដ្ឋធម្មនុញ្ញ)។ រដ្ឋសភារអាចត្រូវបានរំលាយមុនផុតនីតិកាល បើសិនរាជរដ្ឋាភិបាលត្រូវបានទម្លាក់ពីរដងក្នុងរយៈពេល ១២ខែ។ ព្រឹទ្ធសភា មិនអាចត្រូវរំលាយមុនចប់នីតិកាលបានទេ។

យោងមាត្រា ១៥១ថ្មី នៃរដ្ឋធម្មនុញ្ញ ផ្តល់សិទ្ធិផ្តួចផ្តើមគំនិតសើរើ ឬ ផ្តួចផ្តើមគំនិតធ្វើវិសោធនកម្ម រដ្ឋធម្មនុញ្ញដល់ប្រធានរដ្ឋសភា ឬ តាមសេចក្តីស្នើរបស់តំណាងរាស្ត្រមួយភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល។ រដ្ឋធម្មនុញ្ញពុំបានផ្តល់សិទ្ធិផ្តួចផ្តើមគំនិតនេះដល់ព្រឹទ្ធសភាទេ។

សមាជិករដ្ឋសភា ឬ សមាជិកព្រឹទ្ធសភា មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ដូចគ្នា។ សេចក្តីស្នើច្បាប់ណាដែលផ្តួចផ្តើមធ្វើដោយសមាជិកព្រឹទ្ធសភា ត្រូវតែបញ្ជូនទៅឱ្យរដ្ឋសភាពិនិត្យ និងអនុម័ត ជាលើកដំបូង រួចហើយទើបបញ្ជូនមកព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់ ស្របតាមមាត្រា១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ។

រដ្ឋសភាមានអំណាចតាមច្បាប់ក្នុងការចោទសួរ ដេញដោល និងអនុម័តញត្តិបន្ទោស ដកហូត តំណែង ឬរំលាយរាជរដ្ឋាភិបាល ។ តែនៅក្នុងការអនុវត្តជាក់ស្តែងក្នុងសភានានាលើពិភពលោក ទោះបីជាមានគណបក្សប្រឆាំងនៅក្នុងរដ្ឋសភាយ៉ាងណាក្តី ការប្រើអំណាចត្រួតពិនិត្យនេះមានប្រសិទ្ធភាពមិន សូវខ្ពស់ទេ ព្រោះរដ្ឋសភាជាអ្នកបង្កើតរដ្ឋាភិបាល ហើយរបបសំឡេងភាគច្រើនតែងតែគាំទ្ររដ្ឋាភិបាល។ ចរិតរបស់រដ្ឋសភា ជាទូទៅជាប់ជំពាក់នឹងនយោបាយ ដោយមានជម្រើស២៖ គាំទ្រ ឬ ក៏ប្រឆាំងរដ្ឋាភិបាល ។ សម្រាប់ព្រឹទ្ធសភាចរិតទូទៅគឺមិនមែនប្រឆាំង ឬ គាំទ្ររដ្ឋាភិបាលឡើយ ផលិតច្បាប់ឱ្យ បានល្អជាគោលដៅអាទិភាពរបស់ព្រឹទ្ធសភា។ ការផលិតច្បាប់បានល្អ គឺមិនចំណុះបរិយាកាសនយោបាយ និងកាលៈទេសៈឡើយ។ ព្រឹទ្ធសភាមិនប្រឈមនឹងរដ្ឋាភិបាលដូចរដ្ឋសភា ដោយប្រើញត្តិ បន្ទោសដើម្បីដកហូតមុខតំណែងសមាជិករដ្ឋាភិបាល ឬ រំលាយរដ្ឋាភិបាលឡើយ។ ជាទូទៅព្រឹទ្ធសភា

ជាកូនជញ្ជីង១ ដើម្បីធ្វើឱ្យច្បាប់មានតុល្យភាព ដែលអាចទទួលយកបានពីរដ្ឋសភារដ្ឋាភិបាល និងពីសំណាក់ប្រជាពលរដ្ឋ។ គ្មានស្ថាប័នណាមួយអាចប្រទូកនៅក្នុងការដ្ឋាននេះបានឡើយ លើកលែងតែក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានសិទ្ធិសម្រេចអំពីធម្មនុញ្ញភាពនៃច្បាប់មុននឹងប្រកាសឱ្យប្រើ ហើយ សម្រាប់តែច្បាប់ធម្មនុញ្ញ និងច្បាប់រៀបចំអង្គការតែប៉ុណ្ណោះ ។ ដូច្នេះច្បាប់ជាទូទៅ ចាំបាច់ត្រូវការ សំឡេងពិនិត្យ និងឲ្យយោបល់របស់ព្រឹទ្ធសភា ។ ផ្ដើមចេញពីចរិតខុសគ្នានេះ យោបល់ និងការឆ្លុះបញ្ចាំងរបស់ព្រឹទ្ធសភាអាចខុសប្លែកគ្នាពីរដ្ឋសភា ។ យោបល់ និងការឆ្លុះបញ្ចាំងរបស់ព្រឹទ្ធសភា មានលក្ខណៈស្ថាបនាតាមរយៈការសិក្សាស្រាវ ជ្រាវ វាយតម្លៃ កំណត់នូវចក្ខុវិស័យ និងផ្ដល់អនុសាសន៍កែលម្អ។

រដ្ឋសភា និងព្រឹទ្ធសភាអាចប្រជុំរួមគ្នាជាសមាជ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ(រដ្ឋធម្មនុញ្ញមាត្រា១១៦ថ្មី)។

### ៥.៤ បទប្បញ្ញត្តិពិសេស ចែងក្នុងរដ្ឋធម្មនុញ្ញ

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្រោយធ្វើវិសោធនកម្មទាក់ទងទៅនឹងការការបង្កើតស្ថាប័នព្រឹទ្ធសភានៅកម្ពុជា ឃើញថាមានបញ្ញត្តិអំពីចំណុចមួយចំនួនដែលបានបង្ហាញអំពីអំណាច របស់ព្រឹទ្ធសភា នៅក្នុងនាមជាស្ថាប័នកំពូលមួយរបស់រដ្ឋ។ បទប្បញ្ញត្តិពិសេសទាំងនោះរួមមានដូចជា ៖

- ក្នុងករណីព្រះមហាក្សត្រទ្រង់អវត្តមាន (រដ្ឋធម្មនុញ្ញ មាត្រា៣០ថ្មី)។ នៅពេលព្រះមហាក្សត្រទ្រង់ចូលទិវង្គត ឬទ្រង់ប្រឈួនជាទម្ងន់ ប្រធាន ព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្ដីទី ក្នុងឋានៈជាព្រះរាជានុសិទ្ធិ នៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញ មាត្រា១១ថ្មី និងមាត្រា១២ថ្មី )។ នេះជាការធានាស្ថិរភាព និងនិរន្តរភាពរបស់រដ្ឋ។
- ប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ នៃព្រឹទ្ធសភា ជាសមាសភាពនៃក្រុមប្រឹក្សា រាជសម្បត្តិ (រដ្ឋធម្មនុញ្ញ មាត្រា១៣ថ្មី)។
- នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈ ដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា (រដ្ឋធម្មនុញ្ញ មាត្រា២២ ថ្មី)។
- ព្រះមហាក្សត្រទ្រង់ប្រកាសសង្គ្រាម ក្រោយការអនុម័តរបស់រដ្ឋសភា និងព្រឹទ្ធសភា (រដ្ឋ- ធម្មនុញ្ញ មាត្រា២៤ថ្មី)។

- ព្រឹទ្ធសភា មានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល (រដ្ឋធម្មនុញ្ញ មាត្រា ១១២ថ្មី)។ នេះជាការធានាប្រក្រតីភាព នៃជីវភាពរបស់រដ្ឋ ដើម្បីចៀសវាង វិបត្តិតូច និងធំទាំង ឡាយ។
- ការស្នើពិនិត្យធម្មនុញ្ញភាពនៃច្បាប់៖ ប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភា ចំនួនមួយភាគបួន អាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័ត ទៅឲ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យមុននឹងច្បាប់នោះត្រូវយកទៅប្រកាសឱ្យប្រើ(រដ្ឋធម្មនុញ្ញមាត្រា១៤០ថ្មី)។ ក្រោយពី ច្បាប់ណាមួយត្រូវបានប្រកាសឲ្យប្រើប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភាចំនួន មួយភាគ បួនអាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យពីធម្មនុញ្ញភាពនៃច្បាប់នោះ (រដ្ឋធម្មនុញ្ញមាត្រា ១៤១ ថ្មី)។
- រដ្ឋធម្មនុញ្ញមាត្រា ១១៤ថ្មី (មួយ) អនុញ្ញាតឲ្យព្រឹទ្ធសភាបង្កើតគណៈកម្មការ ផ្សេងៗ តាមការចាំបាច់។
- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា មាត្រា ៤ ចែងថា ប្រធានព្រឹទ្ធសភាជាប្រធានសមាជ។